អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the
Courts of Cambodia

ជូន៖ សហចៅក្រមស៊ើបអង្កេត នៃការិយាល័យ
សហចៅក្រមស៊ើបអង្កេត

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 12-Feb-2013, 11:38
CMS/CFO: Sann Rada

Isaac Endeley
ប្រធានអង្គភាពគាំពារការការពារក្តី

ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១២

**កម្មវត្ថុ: ការចាត់តាំងសហមេធាវី ឲ្យធ្វើជាតំណាងលោក មាស មុត ដែលជាជនសង្ស័យក្នុងសំណុំរឿង ០០៣**

លោកសហចៅក្រមជាទីគោរព

១. បន្ថែមពីលើលិខិតចុះថ្ងៃទី ៦ ខែ មីនា ឆ្នាំ ២០១២ ដែលអតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង បានណែនាំដល់អង្គភាពគាំពារការការពារក្តី ឲ្យធ្វើការចាត់តាំងមេធាវីការពារក្តី ដើម្បីធ្វើជាតំណាងជនសង្ស័យនីមួយៗ នៅក្នុងសំណុំរឿង ០០៣ អនុលោមតាមវិធាន ១១(២)(ង)(ច)(ឆ)(ជ) និង (ញ) នៃវិធានផ្ទៃក្នុង ខ្ញុំមានកិត្តិយសសូមជំរាបលោកសហចៅក្រមដូចតទៅ៖

២. គោរពតាមការណែនាំ និងដើម្បីធានានូវសិទ្ធិរបស់ជនសង្ស័យ ស្របតាមវិធាន ២១ និង ២២ នៃវិធានផ្ទៃក្នុងនោះ អង្គភាពគាំពារការការពារក្តី បានចុះបំពេញបេសកកម្មដល់ទីកន្លែង ដើម្បីជួបជនសង្ស័យកាលពីថ្ងៃទី ១៤ ដល់ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១២ និង ពីថ្ងៃទី ២៥ ដល់ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១២។ នៅពេលនោះ



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

Original EN: 00870369-00870370

លោក មាស មុត ដែលជាជនសង្ស័យក្នុងសំណុំរឿង ០០៣ មិនបានស្នើសុំឲ្យមានការចាត់តាំងមេធាវីការពារក្តីនោះឡើយ។

៣. នៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១២ ខ្ញុំបានទទួលលិខិតមួយច្បាប់ពីលោក មាស មុត ស្នើសុំឲ្យធ្វើការចាត់តាំងលោក អាង ឧត្តម និងលោក Michael G. Karnavas ជាសហមេធាវីការពារក្តីឲ្យរូបគាត់។ លោក អាង ឧត្តម និងលោក Michael G. Karnavas ជាមេធាវីជាតិ និងមេធាវីអន្តរជាតិ ដែលកំពុងតែធ្វើជាតំណាងឲ្យលោក អៀង សារី ដែលជាជនជាប់ចោទក្នុងសំណុំរឿង ០០២ នៅចំពោះមុខ អ.វ.ត.ក។ នៅក្នុងលិខិតនោះលោក មាស មុត បានលះបង់នូវរាល់ទំនាស់នានាដែលកើតឡើងពីការដែលមេធាវីទាំងពីររូបត្រូវធ្វើជាតំណាងឲ្យរូបលោក និងលោក អៀង សារីក្នុងពេលជាមួយគ្នា ហើយលោកក៏បានបញ្ជាក់ពីចេតនាក្នុងការប្រើប្រាស់សិទ្ធិនៅស្ងៀមមិនបញ្ចេញមតិយោបល់នៅចំពោះមុខ អ.វ.ត.ក។ ខ្ញុំក៏បានទទួលលិខិតមួយច្បាប់ពីលោក អៀង សារី ដែលបានលះបង់នូវរាល់ទំនាស់នានាដែលកើតឡើងពីការដែលមេធាវីទាំងពីររូបត្រូវធ្វើជាតំណាងឲ្យរូបលោក និងលោក មាស មុត ក្នុងពេលជាមួយគ្នាផងដែរ។

៤. ខ្ញុំបានជួបលោក មាស មុត កាលពីថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១២ ដើម្បីបញ្ជាក់ពីការជ្រើសរើសយកសហមេធាវីនេះ។ លោក មាស មុត បានបញ្ជាក់ថា គាត់ចង់ឲ្យ លោក អាង ឧត្តម និងលោក Michael G. Karnavas ធ្វើជាមេធាវីតំណាងរបស់គាត់ ហើយគាត់បានធ្វើសេចក្តីសម្រេចចិត្តនេះដោយខ្លួនឯង ហើយគាត់ក៏ដឹងថាមេធាវីទាំងពីររូបនេះក៏កំពុងធ្វើជាតំណាងឲ្យបុគ្គលម្នាក់ផ្សេងទៀត នៅចំពោះមុខ អ.វ.ត.ក ផងដែរ។ លោក មាស មុតក៏បានបញ្ជាក់បន្ថែមថា គាត់យល់អំពីអត្ថន័យនៃលិខិតលះបង់សិទ្ធិ ដែលគាត់បានចុះហត្ថលេខា ពាក់ព័ន្ធទៅនឹងទំនាស់នានាដែលអាចកើតមានឡើង ទាក់ទងទៅនឹងបុគ្គលផ្សេងទៀតដែលត្រូវបានតំណាងដោយសហមេធាវីរបស់គាត់។

៥. លោក មាស មុត បានជ្រើសរើសប្រើប្រាស់សិទ្ធិរបស់គាត់ដូចមានចែង ក្នុងវិធាន ២២(១)(ខ) នៃវិធានផ្ទៃក្នុងដើម្បីស្នើសុំការតំណាងតាមផ្លូវច្បាប់ ដែលត្រូវផ្តល់ជូនគាត់ដោយអង្គការសហប្រជាជាតិ ដោយសារតែភាពទល់ក្ររបស់គាត់។ ខ្ញុំបានពិនិត្យមើលទម្រង់លេខ៨៖ ការប្រកាសពីមធ្យោបាយ ដែលក្នុងទម្រង់នេះលោក មាស មុត បានប្រកាសថាគាត់គឺជាជនក្រីក្រ។ ខ្ញុំក៏សូមរំលឹកផងដែរពីខ្លឹមសារនៃការពិភាក្សាដោយផ្ទាល់រវាងខ្ញុំជាមួយលោក មាស មុត កាលពីខែ កក្កដា ឆ្នាំ ២០១២ ដែលក្នុងពេលនោះគាត់បានជម្រាបមកខ្ញុំថាគាត់មិនមានលទ្ធភាពក្នុងការចំណាយសម្រាប់ការតំណាងតាមផ្លូវច្បាប់សម្រាប់ខ្លួនគាត់ទេ។ បន្ថែមពីលើនេះទៀត

T.E.



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

Original EN: 00870369-00870370

កាលពីថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១២ ខ្ញុំបានទូរស័ព្ទទៅលោក មាស មុត ហើយគាត់បានបញ្ជាក់ដដែលថាគាត់គឺជាជនក្រីក្រ។

៦. ប៉ុន្តែដោយសារតែព័ត៌មានសំខាន់ៗមួយចំនួនដែលខ្ញុំទើបតែទទួលបានក្នុងពេលថ្មីៗនេះ ខ្ញុំមិនទាន់ជឿជាក់នៅឡើយថា លោក មាស មុត ពិតជាជនក្រីក្រ។ អនុលោមតាមវិធាន ១១.៦ នៃវិធានផ្ទៃក្នុង តម្រូវឱ្យខ្ញុំត្រូវ "សម្រេចអំពីជនណាមួយជាជនក្រីក្រ និងការចាត់តាំងមេធាវីការពារជនក្រីក្រ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ ដែលកំណត់នៅក្នុងបទបញ្ជារដ្ឋបាលនៃអង្គភាពគាំពារការការពារក្តី"។ ហេតុដូច្នេះ ខ្ញុំមានបំណងធ្វើការស៊ើបអង្កេតឯករាជ្យមួយទៅលើទ្រព្យសម្បត្តិ និងស្ថានភាពហិរញ្ញវត្ថុរបស់លោក មាស មុត មុននឹងធ្វើការសម្រេចថា តើសហមេធាវីការពារក្តី លោក មាស មុត ត្រូវទទួលការទូទាត់តាមគម្រោងជំនួយផ្លូវច្បាប់របស់ អ.វ.ត.កឬទេ។ ខ្ញុំបានពិភាក្សាបញ្ហានេះជាមួយ លោក មាស មុត ព្រមទាំងសហមេធាវីរបស់គាត់រួចហើយ។

៧. ក្នុងពេលជាមួយគ្នានេះ ដើម្បីការពារសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ លោក មាស មុត និងដើម្បីធានាថាគាត់ត្រូវបានតំណាងដោយមេធាវីដែលគាត់បានជ្រើសរើសនោះ សហមេធាវីបានយល់ព្រមបំពេញការងារដោយផ្អែកលើមូលដ្ឋានស្ម័គ្រចិត្តមិនគិតកម្រៃ រហូតដល់ពេលដែលខ្ញុំអាចធ្វើការសម្រេចទៅលើភាពក្រីក្រ។ ដោយផ្អែកទៅលើមូលដ្ឋាននៃការយោគយល់គ្នានេះ ទើបនៅថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ ខ្ញុំបានធ្វើការចាត់តាំងជាផ្លូវការ លោក អាង ឧត្តម និងលោក Michael G. Karnavas ជាសហមេធាវីការពារក្តីលោក មាស មុត ក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក។

៨. ការពន្យាពេលក្នុងការចាត់តាំងមេធាវីនេះ គឺបណ្តាលមកពីមូលហេតុមួយចំនួនដូចជាភាពមិនច្បាស់លាស់ថា តើតាមវិធាន និងបញ្ញត្តិរបស់អង្គការសហប្រជាជាតិ ស្តីពីហិរញ្ញវត្ថុ អ្នកជាប់កិច្ចសន្យាឯករាជ្យ ដូចជាមេធាវីជាដើមនោះ អាចទទួលបានការទូទាត់ចំពោះកិច្ចសន្យាច្រើនដែលត្រូវធ្វើក្នុងពេលជាមួយគ្នាដែរឬទេ។ បន្ទាប់ពីបានពិភាក្សាជាមួយការិយាល័យដែលពាក់ព័ន្ធ ទើបខ្ញុំប្រាកដថាការចាត់តាំងមេធាវីឱ្យការពារក្តីសំណុំរឿងច្រើន គឺមិនរំលោភទៅលើវិធាន និងបញ្ញត្តិដែលនៅជាធរមាននោះទេ។ លើសពីនេះទៅទៀត គម្រោងជំនួយផ្លូវច្បាប់មិនបានហាមឃាត់ការចាត់តាំងមេធាវីមួយរូបឱ្យធ្វើជាតំណាងជនសង្ស័យ ជនជាប់ចោទ ឬម្ចាស់បណ្តឹងសាទុក្ខជាច្រើនរូប នៅចំពោះមុខ អ.វ.ត.កនោះឡើយ។ បន្ថែមលើនេះ ដោយសារតែសំណុំរឿង ០០២ និង ០០៣ ស្ថិតក្នុងដំណាក់កាលផ្សេងៗគ្នានៃកិច្ចដំណើរការនីតិវិធី ព្រមទាំងដោយសាររចនាសម្ព័ន្ធអង្គភាពរបស់ អ.វ.ត.ក ទើបខ្ញុំជឿជាក់ថាការចាត់តាំងនេះ នឹងមិនបង្កឱ្យមានបញ្ហាផ្នែកកាលវិភាគក្នុងកិច្ចដំណើរការនីតិវិធីនោះឡើយ។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

Original EN: 00870369-00870370

៩. នៅថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១២ ខ្ញុំក៏បានជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងអំពីលទ្ធភាពដែលសហមេធាវីការពារក្តីលោក អៀង សារី អាចត្រូវទទួលការចាត់តាំងឱ្យធ្វើជាមេធាវីតំណាងជនសង្ស័យក្នុងសំណុំរឿង ០០៣។ ក្នុងលិខិតឆ្លើយតបចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានជម្រាបមកខ្ញុំ ដោយមិនបានបញ្ជាក់ឈ្មោះថា ជនសង្ស័យមួយរូបក្នុងសំណុំរឿង ០០៣ ប្រហែលជាអាចត្រូវបានកោះហៅមកធ្វើជាសាក្សីក្នុងសំណុំរឿង ០០២។

១០. ក្នុងការត្រួតពិនិត្យទៅលើសំណើសុំឱ្យមានការចាត់តាំងមេធាវីនោះ ខ្ញុំបានពិចារណាទៅលើការបង្ហាញពីការចង់បានរបស់លោក មាស មុត ដែលរួមមាន បទពិសោធន៍ជារួមរបស់មេធាវីទាំងក្នុងវិស័យច្បាប់មនុស្សធម៌ និងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ, កម្រិតនៃការយល់ដឹងរបស់មេធាវីចំពោះវិធាន ការអនុវត្ត ព្រមទាំងនីតិវិធីដែលកំពុងអនុវត្តនៅ អ.វ.ត.ក, ចំណេះដឹងរបស់មេធាវីក្នុងបរិបទនយោបាយ និងប្រវត្តិសាស្ត្រនៃសម័យកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងការលះបង់នូវរាល់ទំនាស់នានាដែលអាចមាន។ ដូចដែលបានបញ្ជាក់ពីខាងលើរួចមកហើយ ការអះអាងរបស់លោក មាស មុត អំពីភាពក្រីក្រ ចាំបាច់ត្រូវមានការត្រួតពិនិត្យដោយឯករាជ្យ។

១១. យោងតាមការរង់ចាំលើការសម្រេចអំពីភាពក្រីក្រ ដែលកំពុងតែបន្តនោះ ខ្ញុំបានចាត់តាំងលោក អាង ឧត្តម ជាសហមេធាវីការពារក្តីជាតិ និងលោក Michael G. Karnavas ជាសហមេធាវីការពារក្តីអន្តរជាតិ សម្រាប់លោក មាស មុត ដែលជាជនសង្ស័យក្នុងសំណុំរឿង ០០៣ នៅចំពោះមុខ អ.វ.ត.ក។

១២. សូមលោកសហចៅក្រមស៊ើបអង្កេតមេត្តាទទួលជ្រាបអំពីការចាត់តាំងនេះ។

ដោយការគោរពដោយស្មោះអំពីខ្ញុំ

Isaac Endeley
ប្រធានអង្គភាពគាំពារការការពារក្តី

ចម្លងជូន៖ ឯកឧត្តម ក្រាញ់ តូនី ប្រធានការិយាល័យរដ្ឋបាលស្តីទី
លោក Knut Rosandhaug អនុប្រធានការិយាល័យរដ្ឋបាល/ អ្នកសម្របសម្រួល UNAKRT

ជូនភ្ជាប់៖ ទម្រង់ទី៧ សំណើជ្រើសតាំង/ ចាត់តាំងសហមេធាវី



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.
Original EN: 00870369-00870370